# សុន្ទរកថាគន្លឹះ

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា-លើកទី ៣

## វិមានរាជរដ្ឋាភិបាល, ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១០

****+****

- *ឯកឧត្តមប្រធានវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា*
- *ឯកឧត្តម លោកជំទាវ តំណាងប្រទេស និង ភ្នាក់ងារជាដៃគូ*
- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ !*

**1.** ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង សេចក្តីរីករាយជាអនេក ដោយបានមកជួបប្រជុំជាថ្មីម្តងទៀតជាមួយតំណាងរបស់សហគមន៍អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍របស់យើង ។ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមក្នុង **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា-លើកទី ៣** នេះ ។

**2.** វេទិការបស់យើងលើកនេះ គឺផ្តោតការយកចិត្តទុកដាក់ទៅលើគោលដៅដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២** តាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ២០០៩-២០១៣** ដែលរដ្ឋសភាទើបបានអនុម័ត កាលពីថ្ងៃទី ៣១ ខែ ឧសភា កន្លងទៅនេះ ។ ប្រធានបទនៃវេទិកាលើកទី ៣ របស់យើងនាពេលនេះ ក៏ជាការឆ្លុះបញ្ចាំងនូវការបន្តប្តេជ្ញាចិត្តដ៏មោះមុតឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចឱ្យបាននូវកម្មវិធីនយោបាយ ដែលបានដាក់ចេញសម្រាប់នីតិកាលទី ៤ ឆ្លើយតបនឹងសេចក្តីទុកចិត្ត និង ការគាំទ្រដ៏ច្រើនលើសលប់របស់ប្រជាជនកម្ពុជា ដែលបានសម្តែងឆន្ទៈក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ដែលបានប្រព្រឹត្តទៅក្នុងខែ កក្កដា ឆ្នាំ ២០០៨ កន្លងទៅនេះ ។ រាជរដ្ឋាភិបាលនឹងនៅតែបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនតទៅទៀត ដើម្បីដឹកនាំនាវាកម្ពុជាឱ្យបន្តធ្វើដំណើរលើមាគ៌ានៃការអភិវឌ្ឍគ្រប់វិស័យ ក្នុងនោះ មានការកាត់បន្ថយភាពក្រីក្រ ការពង្រឹងសុខសន្តិភាព និង ស្ថិរភាពនយោបាយ អភិបាលកិច្ចល្អ កម្មវិធីកំណែទម្រង់នានា កិច្ចសហប្រតិបត្តិការអន្តរជាតិ ការលើកកម្ពស់វិស័យឯកជន ការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសមត្ថភាព ការធានាសុខមាលភាពសង្គមជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និង ក្នុងពិភពលោក ។ ជារួម រាជរដ្ឋាភិបាលកម្ពុជាបាន និង កំពុងតែបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និង ធ្វើឱ្យកាន់តែស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់នានា ដែលបានដាក់ចេញកន្លងមក ពីព្រោះថា កិច្ចការកែទម្រង់ជាការងារស្លាប់រស់របស់កម្ពុជា ។

3. ក្នុងទស្សនៈនេះ ដូចនៅក្នុងវេទិកាលើកមុនៗដែរ យើងមកជួបគ្នានៅថ្ងៃនេះ មិនមែនគ្រាន់តែបូកសរុបនូវលទ្ធផលនៃវឌ្ឍនភាពការងារ និង ពិនិត្យនូវសកម្មភាពកែទម្រង់របស់យើងក្នុងរយៈពេលកន្លងមកតែប៉ុណ្ណោះទេ ប៉ុន្តែ រឹតតែសំខាន់ណាស់ទៅទៀតនៅពេលនេះ គឺយើងត្រូវធ្វើការពិគ្រោះយោបល់ផងដែរ លើទិដ្ឋភាពគន្លឹះ ផ្សេងៗ ដើម្បីជំរុញនូវវឌ្ឍនភាពការងារអភិវឌ្ឍន៍កម្ពុជានាពេលខាងមុខ ។ វេទិកាលើកទី ៣ នេះ ប្រារព្ធឡើងចំពេលដែលវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលលោក បានថមថយចុះទៅវិញ ហើយសញ្ញានៃការងើបឡើងវិញ ក៏បានបង្ហាញរូបរាងកាន់តែច្បាស់ឡើង ថ្វីត្បិតថា ប្រព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសកលលោក នៅត្រូវបន្តប្រឈមនឹងហានិភ័យចម្បងៗមួយចំនួនក៏ដោយ ។ ក្នុងកាលៈទេសៈនេះ នៅពីក្រោយដានដែលបន្សល់ទុកដោយផលប៉ះពាល់អាក្រក់នៃវិបត្តិសេដ្ឋកិច្ចសកលលោកនោះ គឺយើងអាចមើលឃើញដោយភាពប្រាកដប្រជាជាងមុនពីសុខុមាលភាពរួមនៃសេដ្ឋកិច្ចកម្ពុជា និង មូលដ្ឋានគ្រឹះ ដែលទ្រទ្រង់សេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីបានប្រឈមនឹងការបក់បោកពីព្យុះនៃវិបត្តិ ក៏ដូចជាលទ្ធផលនៃកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា នៅក្នុងដំណាក់កាលដ៏លំបាកលំបិននោះ ។ ក្នុងន័យនេះ គេមិនអាចវាយតម្លៃដំណើរការនៃការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចរបស់កម្ពុជាបានសព្វជ្រុងជ្រោយ ដោយមិនបានគិតពីឆន្ទៈ និងការប្ដេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាល និងប្រជាជនទាំងអស់របស់ប្រទេសនេះ ក្នុងការរួបរួមកម្លាំងគ្នា ដើម្បីជំនះគ្រប់ឧបសគ្គឆ្លងកាត់វិបត្តិលើកនេះបាននោះឡើយ ។

4. ដូច្នេះ មុននឹងគូសបញ្ជាក់ដោយសង្ខេបអំពីសមិទ្ធផលធំៗ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងរយៈពេលកន្លងមក ពិសេសចាប់តាំងពីការប្រារព្ធវេទិកាលើកមុន នាដំណាច់ឆ្នាំ ២០០៨ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជាទាំងមូល ថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងវិស័យឯកជន ដែលបានចូលរួមវិភាគទានដ៏ឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបានជាមួយរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជាទាំងមូល ក្នុងឆ្នាំកន្លងមក ពិសេសក្នុងខណៈដែលយើងត្រូវពុះពារជំនះបញ្ហាប្រឈម និង វិញ្ញាសារសាកល្បងធំៗជាច្រើន ដែលវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលបានដាក់ចេញមក ។ ជាមួយគ្នានេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងនៅតែបន្តកិច្ចសហប្រតិបត្តិការបែបនេះ ជាដរាបតទៅទៀត ក្នុងស្មារតីនៃភាពជាដៃគូស្មោះត្រង់ និង ពិតប្រាកដ ការទទួលខុសត្រូវទៅវិញទៅមក និង ការគោរពដល់ភាពជាម្ចាស់ ។ រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងមកដោយឆន្ទៈពិតប្រាកដរបស់ប្រជាជនកម្ពុជានេះ នឹងនៅតែបន្តប្ដេជ្ញាចិត្តឥតរាថយក្នុងការអនុវត្តអាណត្តិកិច្ចរបស់ខ្លួន ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយតម្កល់ផលប្រយោជន៍ជាតិ និង បំណងប្រាថ្នារបស់ប្រជាជនកម្ពុជាជាអទិភាពជានិច្ចកាល ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

5. ឆ្នាំ ២០០៩ គឺជាឆ្នាំដ៏លំបាកសម្រាប់កម្ពុជា ។ កលិយុគហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលលោកបានបង្កជាហានិភ័យ ដែលគំរាមដល់សមិទ្ធផលជាផ្លែផ្កានៃការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ដែលយើងសម្រេចបានក្នុងរយៈពេលកន្លងមក ។ បច្ច័យអាក្រក់ដែលបណ្ដាលមកពីវិបត្តិសកលលោកលើកនេះ បានបក់បោកមកលើប្រព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកម្ពុជា នាំឱ្យមានការស្រកស្រុតចុះនៃប្រភពហិរញ្ញវត្ថុ និង លំហូរទុនវិនិយោគឯកជន ការធ្លាក់ចុះនៃសេចក្ដីត្រូវការនៅក្នុងទីផ្សារសំខាន់ៗរបស់កម្ពុជា និង ការថមថយចុះនូវចំនួនទេសចរដែលមក

ទស្សនាកម្ពុជា ។ ក្នុងនោះ វិស័យដែលយើងបានរំពឹងថានឹងទទួលរងផលប៉ះពាល់ខ្លាំងជាងគេ រួមមាន វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង ទីផ្សារអចលនៈទ្រព្យ ។ យើងបានរំពឹងទុកផងដែរថា បច្ច័យអាក្រក់នៃវិបត្តិនេះនឹងធ្វើឱ្យជីវិភាពរស់នៅរបស់ប្រជាជន ពិសេសអ្នកដែលរស់នៅពឹងអាស្រ័យនឹងវិស័យសំខាន់ៗទាំងនេះ ទទួលរងនូវហានិភ័យ និង ផលប៉ះពាល់ជាអវិជ្ជមានយ៉ាងដំណំ ។ ទន្ទឹមនឹងនេះ សមិទ្ធផលជាផ្លែផ្កានៃកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ក៏ត្រូវបានប្រទាញប្រទង់ដោយភាពមិនប្រាកដប្រជានៃបច្ច័យអាក្រក់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលលោក ដែលធ្វើឱ្យដំណើរឆ្ពោះទៅមុខរបស់កម្ពុជាក្នុងការឈានទៅសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ត្រូវជួបប្រទះនូវបញ្ហាប្រឈម និង ឧបសគ្គទ្វេដងដែលមិនត្រឹមតែអាចជាកត្តារារាំងដល់ការសម្រេចគោលដៅសម្រាប់វិស័យមួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងគំរាមបំផ្លាញសមិទ្ធផលដែលយើងសម្រេចបាន និង សន្សំបានក្នុងរយៈកាលកន្លងមកទៀតផង ។

**6.** ប៉ុន្តែ យ៉ាងណាក៏ដោយ ក្នុងការប្រឈមមុខចំពោះព្យុះនៃវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងឆ្នាំកន្លងទៅ នេះរាជរដ្ឋាភិបាលកម្ពុជាមានការគិតគូច្បាស់លាស់របស់ខ្លួន សម្រាប់ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនោះ ដោយបានដាក់ចេញ និង អនុវត្ត ក្នុងស្មារតីសកម្មគ្រប់គ្រង នូវវិធានការគោលនយោបាយគន្លឹះៗ ដើម្បីទប់ទល់ និងសម្រាល នូវបច្ច័យអាក្រក់ដែលបណ្តាលមកពីវិបត្តិទាំងនេះ ។ ទស្សនវិជ្ជាគ្រឹះរបស់យើងនៅក្នុងការខិតខំជំនះផលវិបាកអក្រក់បណ្តាលមកពីវិបត្តិនេះ គឺការប្រឹងប្រែងក្តាប់ឱ្យបានជាប់នូវជីពចរសេដ្ឋកិច្ចជាតិ និង ការធានាឱ្យបាននូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមួយដែលមានលក្ខណៈគត់មត់ មានភាពអំណោយផលសម្រាប់សេដ្ឋកិច្ច និង ពិសេសបំផុត គឺការធានានូវលំនឹងនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដែលអាចនិយាយតាមភាសាសាមញ្ញថា ***«យើងត្រូវធានាឱ្យប្រជាជនមានអង្ករច្រកឆ្នាំង»*** ។ ក្នុងក្របខ័ណ្ឌនៃទស្សនៈវិជ្ជានេះ កម្ពុជាបានឆ្លើយតបយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព ទៅនឹងវិបត្តិ តាមរយៈការធ្វើអន្តរាគមន៍ ***ផ្នែកថវិកាក្នុងកម្រិតមធ្យម*** ក្នុងទិសដៅ ***រក្សាស្ថិរភាពរូបិយវត្ថុ*** និង ***គាំទ្រចីរភាពនៃកំណើនសេដ្ឋកិច្ច*** របស់ខ្លួន ។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ដែលដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ត្រូវបានប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និង តាមដានការអនុវត្តគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងវិបត្តិ ។

**7.** នៅក្នុងបរិបថនៃយន្តការសម្របសម្រួលនេះ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការដ៏រស់រវើកមួយចំនួនក្នុងការគ្រប់គ្រងទុនបម្រុងកាតព្វកិច្ច ការកែលម្អការត្រួតពិនិត្យ ការធ្វើនិយ័តកម្មតឹងរឹង តាមរយៈការរឹតត្បិតបទបញ្ញត្តិ និង ការពង្រឹងអធិការកិច្ចនៅនឹងកន្លែង ។ល។ ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យ និង អភិបាលកិច្ចសាជីវកម្ម ដែលនាំឱ្យធនាគារពាណិជ្ជមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និង ទប់ទល់ចំពោះផលប៉ះពាល់ពីបម្រែបម្រួលលក្ខខណ្ឌសេដ្ឋកិច្ច និង ទីផ្សារ ។

**8.** ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានចាត់វិធានការជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ដោយ ***បង្កើនចំណាយសាធារណៈ*** ដើម្បី ***លើកស្ទួយប្រព័ន្ធគាំពារសុវត្ថិភាពសង្គម*** និង ***ផ្តល់ការបណ្តុះបណ្តាលឡើងវិញ*** ព្រមទាំងស្វះស្វែងរកការងារជូនប្រជាជនរងគ្រោះ ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ពីវិបត្តិ ។ យើងក៏បានបង្កើតឡើងនូវ ***មូលនិធិទ្រទ្រង់ និង អភិវឌ្ឍន៍វិស័យកសិកម្ម*** ដើម្បីបង្កើនផលិតភាពក្នុងវិស័យនេះ និង ធ្វើពិពិធកម្មមូលដ្ឋាន

កំណើនរបស់យើង ។ ***ក្នុងការវិនិយោគសាធារណៈ យើងបានផ្តល់អាទិភាពពិសេសចំពោះការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការបង្កើនផលិតភាព ដើម្បីលើកស្ទួយកំណើនក្នុងវិស័យកសិកម្ម*** ។

**9.** បន្ថែមលើនេះទៀត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំជាសេរីនៃការជួបប្រជុំជាមួយនឹងប្រតិបត្តិករវិស័យឯកជន តាមវិស័យសំខាន់ៗមួយចំនួន ពិសេសវិស័យកាត់ដេរ និង ទេសចរណ៍ ដើម្បីពិភាក្សា និង ដាក់ចេញនូវវិធានការបន្ទាន់មួយចំនួន សំដៅផ្តល់ការគាំទ្រ និង ការសម្រួលបន្ថែមដល់វិស័យទាំងនេះ ដែលបានទទួលរងបច្ច័យអាក្រក់ពីវិបត្តិ ។

**10.** ចំពោះមុខសភាពការណ៍នេះ ឱនភាពថវិកាឆ្នាំ ២០០៩ ត្រូវបានរំពឹងទុកថា នឹងកើនឡើងដល់ជាង ៦% នៃផសស ដែលជាទំហំមួយខ្ពស់ច្រើន ធៀបទៅនឹងឱនភាពថវិកាក្នុងបណ្តាឆ្នាំកន្លងទៅមុនៗ ។

**11.** កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ បានជួយឱ្យយើងជំនះបាននូវបណ្តាបច្ច័យអាក្រក់ពីវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំកន្លងទៅ ហើយរក្សាបានជារួមនូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ។ ជាក់ស្តែង ផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០០៩ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើនវិជ្ជមាន ទោះបីជាអាចក្នុងទំហំតូចក៏ដោយ ដោយសារវិស័យកសិកម្ម និង សេវា រក្សាបានកំណើនសមរម្យល្អប្រសើរ ពិសេសគឺវិស័យកសិកម្ម ដែលសម្រេចបាននូវកំណើនក្នុងកម្រិតជាង ៥% ដែលជាប្រការជួយឱ្យយើងអាចជួយទប់ទល់បាននឹងការធ្លាក់ចុះក្នុងវិស័យឧស្សាហកម្ម ។ ជាមួយគ្នានេះ ផ្នែកផ្សេងៗនៃវិស័យសេវាសុទ្ធតែត្រូវបានរំពឹងថា នឹងមានកំណើនវិជ្ជមាន លើកលែងតែវិស័យអចលនវត្ថុមួយប៉ុណ្ណោះ ។ វិនិយោគផ្ទាល់ពីបរទេសបានធ្លាក់ចុះមួយចំនួន មកនៅត្រឹមជាង ៥០០ លានដុល្លារ ក្នុងឆ្នាំ ២០០៩ ក៏ប៉ុន្តែ នៅតែជាចំនួនដ៏ច្រើនសម្រាប់ជួយទ្រទ្រង់សេដ្ឋកិច្ចកម្ពុជា ។ វិស័យហិរញ្ញវត្ថុ និង ធនាគារ ក៏ត្រូវបានរក្សាការពារឱ្យមានស្ថិរភាពល្អផងដែរ ។

**12.** ជាមួយគ្នានេះ នៅឆ្នាំ ២០១០ នេះ កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថា នឹងចាប់ផ្តើមស្ទុះឡើងវិញ ដោយត្រូវបានព្យាករណ៍ក្នុងរង្វង់ជុំវិញ ៥% ។ អតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការធ្លាក់ចុះនៃតម្លៃម្ហូបអាហារ ហើយអត្រាប្តូរប្រាក់ត្រូវបានរក្សារឱ្យមានស្ថិរភាពធៀបនឹងប្រាក់ដុល្លារ ។ ទុនបម្រុងអន្តរជាតិសរុបបានបន្តកើនឡើង ពី ២,៣ ពាន់លាន ពីដើមឆ្នាំ មកដល់ប្រមាណ ២,៥ ពាន់លានដុល្លារ នាដើមខែ ឧសភា កន្លងទៅនេះ ដែលអាចទប់ទល់ការនាំចូលបានជាង ៤ ខែ ។ ផ្អែកលើសូចនាករថ្មីៗទាំងនេះ យើងអាចនិយាយបានដោយជឿជាក់ថា ***រាជរដ្ឋាភិបាលបានដឹកនាំសេដ្ឋកិច្ចកម្ពុជា ឱ្យឆ្លងផុតពីដំណាក់កាលលំបាកបំផុតនៃវិបត្តិសេដ្ឋកិច្ច ដូចគ្នានឹងសេដ្ឋកិច្ចដទៃទៀតនៅតំបន់អាស៊ីដែរ ដោយក្នុងដំណើរការដ៏លំបាកលំបិននេះ យើងអាចធានារក្សាបានយ៉ាងគត់មត់នូវស្ថិរភាពវិស័យហិរញ្ញវត្ថុ ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពសង្គម ជាពិសេសលំនឹងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងមូល*** ។

**13.** ពិនិត្យជារួម នៅក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចមកលើជីវភាពប្រជាជន កម្ពុជាអាចមានសភាពខុសៗគ្នាតាម ទីកន្លែង និង ស្រទាប់សង្គម ។ ក៏ប៉ុន្តែ យ៉ាងណាក៏ដោយ មានគ្រួសារចំនួនតែប្រមាណមួយភាគប្រាំនៃចំនួនគ្រួសារសរុបប៉ុណ្ណោះ ដែលមានទំនាក់ទំនងដោយត្រង់ទៅនឹងវិស័យដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិ ពិសេសគឺវិស័យកាត់ដេរ ដែលរាជរដ្ឋាភិបាលបានដាក់វិធានការជួយកាត់បន្ថយសម្រាលផលប៉ះពាល់ទាំងនេះ បានយ៉ាងទាន់ពេលវេលា ។ ផ្ទុយទៅវិញ ដោយសារកំណើនល្អប្រសើរនៅក្នុង

វិស័យកសិកម្ម និង សកម្មភាពសេដ្ឋកិច្ចជនបទ យើងរំពឹងថា ប្រជាជនកម្ពុជាភាគច្រើនលើសលប់ដែលប្រកបរបរកសិកម្មនៅទីជនបទ បានទទួលផលប្រយោជន៍ពីកំណើននេះ ហើយជីវភាពរបស់ពួកគេ ក៏ត្រូវបានលើកតម្កើងបន្ថែមមួយកម្រិតទៀតដែរ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**14.** រាជរដ្ឋាភិបាលនៅតែចាត់ទុកថា អភិបាលកិច្ចល្អ គឺជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និង យុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អ តម្រូវឱ្យមានការប្រតិបត្តិតាមវិធាននៃច្បាប់ ដោយសមភាព មានគណនេយ្យភាព និង តម្លាភាព ។ យើងត្រូវធានាថា អភិបាលកិច្ចល្អ មានវិសាលភាពគ្របដណ្តប់លើគ្រប់ទិដ្ឋភាព និង មានការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងសង្គម ។ ក្នុងន័យនេះ គេមិនអាចនិយាយអំពីអភិបាលកិច្ចល្អ សម្រាប់តែមនុស្សម្នាក់ មនុស្សមួយក្រុម ឬ ផ្នែកមួយនៃសង្គមនោះទេ ពីព្រោះថា កិច្ចការនេះ គឺជាសេចក្តីត្រូវការរួមរបស់សង្គមកម្ពុជាទាំងមូល ទាំងក្នុងពេលបច្ចុប្បន្ន និង តទៅអនាគត ។ ដូច្នេះ រាល់ការអនុវត្តនៅគ្រប់ការដ្ឋានកំណែទម្រង់សំខាន់ៗទាំងអស់របស់រាជ-រដ្ឋាភិបាលត្រូវតែសំដៅឆ្ពោះទៅរកការពង្រឹងអភិបាលកិច្ចល្អ តាមរយៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការ-កែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ រួមទាំងការប្រឆាំងអំពើពុករលួយ ការជំរុញល្បឿននៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារវិមជ្ឈការ និង វិសហមជ្ឈការជាដើម និង ត្រូវតែបន្តធ្វើជាប់មិនដាច់ និងឱ្យកាន់តែស៊ីជម្រៅថែមទៀត តាមរបៀបភ្លៀងរលឹម និង មិនត្រូវដកថយនោះឡើយ ។

**15.** ក្នុងក្របខ័ណ្ឌនៃទស្សនៈនេះ រាជរដ្ឋាភិបាលបានចាត់ទុកថា ការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅតែបន្តជាអាទិភាពសំខាន់បំផុតមួយរបស់ខ្លួននៅក្នុងនីតិកាលទី ៤ នេះ ។ នៅក្នុងស្មារតីនេះ តាំងពីមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើពុករលួយនៅឡើយក៏ដោយ ក៏រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ តាមរយៈ ការដាក់ចេញនូវផែនការសកម្មភាពអភិបាលកិច្ច ការអនុម័ត និងការជំរុញអនុវត្តនូវវិធានការច្បាប់មុតស្រួចជាបន្តបន្ទាប់ ដែលមានរួមបញ្ចូលនូវការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ បទល្មើសដីធ្លី បទល្មើសជលផល កុងត្រូលជជុះ ការរត់ពន្ធទំនិញ ការឃុបឃិតគ្នារវាងឈ្មួញទុច្ចរិត និងមន្ត្រីអនុវត្តច្បាប់ និង សកម្មភាពរំលោភច្បាប់ក្រោមរូបភាពផ្សេងៗទៀត ដែលបានបង្កជាផលវិបាកដល់ជីវភាពប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋស្លូតត្រង់ ។

**16.** រាជរដ្ឋាភិបាលយល់ច្បាស់ថា ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺជាមូលដ្ឋានគតិយុត្តិគន្លឹះមួយមិនអាចខ្វះបាន សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ អាស្រ័យហេតុនេះ យោងតាមការប្តេជ្ញាចិត្តមោះមុតឥតរាថយ ដែលខ្ញុំបានគូសបញ្ជាក់កាលពីវេទិកាលើកទី ២ នាចុងឆ្នាំ ២០០៨ យើងបានធ្វើការយ៉ាងសកម្ម ដើម្បីបញ្ចប់ការរៀបចំ និង ជំរុញអនុម័តច្បាប់នេះ ដោយផ្អែកលើច្បាប់គោលដទៃទៀតដែលជាមូលដ្ឋាននៃច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនេះ ។ បច្ចុប្បន្ននេះ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានរដ្ឋសភា និង ព្រឹទ្ធសភាអនុម័តរួចហើយ ។ ដូច្នេះ បេសកកម្មបន្ទាប់ ដែលមិនអាចខ្វះបាន និង ដែលរាជរដ្ឋាភិបាលប្តេជ្ញាជំរុញសម្រេចឱ្យខាងតែបាននោះ គឺការរៀបចំយន្តការចាំបាច់នានា ដែលតម្រូវដោយច្បាប់ ដើម្បីជាមូលដ្ឋាន

សម្រាប់អនុវត្តច្បាប់នេះ ឱ្យមានប្រសិទ្ធភាព រួមមានទាំងការអប់រំផ្សព្វផ្សាយ និង ការជំរុញអនុវត្តច្បាប់ លិខិតបទដ្ឋាន និង វិធានការជាក់ស្ដែងផ្សេងៗទៀត ដែលមានការពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ និង កម្មវិធីកែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាលផងដែរ ។

**17.** ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តកែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ ដោយជំរុញអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។ កន្លងមកនេះ យើងបានកែលម្អប្រព័ន្ធច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដោយផ្ដោតជាសំខាន់លើការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យបានរឹងមាំ ព្រមទាំងពង្រឹងសមត្ថភាព ឯករាជ្យ និង អព្យាក្រឹត្យភាពនៃស្ថាប័នតុលាការ ដែលជាកត្តាសំខាន់ក្នុងដំណើរការនៃការពង្រឹងនីតិរដ្ឋ ។ ទន្ទឹមនឹងក្រមធំៗជាមូលដ្ឋានចំនួនបួនត្រូវបានប្រកាសឱ្យប្រើរួចហើយ ដែលក្នុងនោះរួមមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់សំខាន់ៗជាច្រើនទៀត ក៏ត្រូវបានចងក្រង និង បញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិ ដើម្បីអនុម័ត ។ ជាមួយនោះ វិធានការវិន័យក៏ត្រូវបានដាក់ចេញ និង អនុវត្តជាបន្តបន្ទាប់ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្របជាមួយនឹងការបង្កើនការយកចិត្តទុកដាក់ដល់ការបណ្ដុះបណ្ដាល និង ពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវវិជ្ជាជីវៈរបស់មន្ត្រីតុលាការ ចៅក្រម និង ព្រះរាជអាជ្ញា ។ ក្នុងនោះ យន្តការសំខាន់ៗ ដូចជា មជ្ឈមណ្ឌលសេវាយុត្តិធម៌ សម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង ការអនុវត្តសាកល្បងនូវតុលាការគំរូជាដើម ក៏ត្រូវបានបង្កើត និង ដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ក្នុងគោលដៅកែលម្អដំណើរការនីតិវិធីតុលាការ និង ជំរុញប្រសិទ្ធភាពប្រព័ន្ធតុលាការ និង សំដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ។

**18.** ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានកំណត់យកកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងគោលដៅប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យក្លាយទៅជារដ្ឋបាលដែលមានលក្ខណៈប្រតិបត្តិការ មានផលិតភាព មានការទទួលខុសត្រូវខ្ពស់ជាងមុន និង មានសមត្ថភាពខ្ពស់ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងជំរុញបង្កើនល្បឿននៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ខ្លួន ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យទៅជាអ្នកផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព មានតម្លាភាព គណនេយ្យភាព និង ឆ្លើយតបចំទិសដៅ និង ទាន់ពេលវេលា តាមសេចក្ដីត្រូវការរបស់ប្រជាជន ។ ក្នុងនេះ អាទិភាពនឹងត្រូវបានផ្ដោតទៅលើការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការពង្រឹងការងារគ្រប់គ្រង និង អភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ ការពង្រឹងការផ្ដល់សេវាសាធារណៈជាមូលដ្ឋាន សេវាអធិបតេយ្យរបស់រដ្ឋពាក់ព័ន្ធនឹងការវិនិយោគ និង ពាណិជ្ជកម្មធុនតូច និង មធ្យម ការពង្រឹងយន្តការ ***«ច្រកចេញ-ចូលតែមួយ»*** និង ការបង្កើតការិយាល័យប្រជាពលរដ្ឋ ។ ក្នុងនោះ យន្តការសម្រាប់ជំរុញប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ដូចជា ***«ទីភ្នាក់ងារប្រតិបត្តិការពិសេស»*** ជាដើម ក៏នឹងត្រូវអនុវត្តឱ្យកាន់តែទូលំទូលាយថែមទៀតផងដែរ ។

**19.** ជាការពិត កាលៈទេសៈដ៏លំបាកនៃវិបត្តិហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសកលក្នុងឆ្នាំកន្លងទៅ បានដាក់សម្ពាធយ៉ាងខ្លាំងមកលើលំហថវិកាកម្ពុជា ។ ប្រការនេះ បានតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការពិនិត្យឡើងវិញជាបន្ទាន់ នូវកញ្ចប់នៃគោលនយោបាយប្រាក់បៀវត្សសម្រាប់កងកម្លាំងប្រដាប់អាវុធ និង មន្ត្រីរាជការ ក្នុងគោលដៅធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ប្រសិទ្ធភាពនៃការអភិវឌ្ឍក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ ។ នៅក្នុងក្របខ័ណ្ឌនេះ យើងបានដាក់ចេញនូវនៃវិធានការដ៏មុតស្រួច

មួយចំនួន រួមមាន ការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ និង មន្ត្រីនគរបាលជាតិ និងការពង្រឹងការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការ កងទ័ព និង នគរបាល ។ល។ ដោយរួមបញ្ចូលទាំងការបញ្ឈប់ជាស្ថាពរ នូវការអនុវត្តកន្សោមអាទិភាព និង ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារផងដែរ ។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់អំពីសេចក្តីត្រូវការក្នុងការធានានូវចិរភាព និង ប្រសិទ្ធភាពនៃការអនុវត្តគម្រោងអភិវឌ្ឍនានា នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់របស់យើង ។ លើមូលដ្ឋាននេះ យើងបានឯកភាពគ្នាប្រើរយៈពេល ៦ ខែ ដើម្បីរៀបចំក្របខណ្ឌថ្មីនៃ ***«ចំណាយប្រតិបត្តិការអាទិភាព»*** ដែលមកដល់ពេលនេះ ក្របខ័ណ្ឌនេះ ត្រូវបានរៀបចំ និង ឯកភាពគ្នារួចហើយ ហើយសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ក៏កំពុងតែត្រូវបានរៀបចំ ក្នុងគោលដៅជំរុញដាក់ឱ្យអនុវត្តក្របខ័ណ្ឌថ្មីនេះឱ្យបាននៅក្នុងខែ កក្កដា ខាងមុខនេះ ។

**20.** យ៉ាងណាមិញ យើងក៏ទទួលស្គាល់ផងដែរថា ដើម្បីសម្រេចបានតាមគោលដៅចម្បងៗនៃកំណែទម្រង់រដ្ឋបាលសាធារណៈដែលបានដាក់ចេញមកនេះ ***នៅក្នុងរយៈពេលមធ្យមខាងមុខ រាជរដ្ឋាភិបាលនៅតែមានសេចក្តី-ត្រូវការចាំបាច់ក្នុងការបន្តជំរុញអនុវត្តកំណែទម្រង់ស៊ីជម្រៅនៃប្រព័ន្ធបៀវត្ស ដោយឈរលើគោលការណ៍ធំៗមួយ-ចំនួន មានជាអាទិ៍ៈ ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងសង្គតិភាព និង សមធម៌នៃប្រព័ន្ធបៀវត្ស*** ។

**21.** ពិតណាស់ថា ការប្រែក្លាយរដ្ឋបាលសាធារណៈរបស់កម្ពុជា ដែលនៅមានអាយុក្មេងខ្ចីនៅឡើយ បន្ទាប់ពីការបញ្ចប់សង្គ្រាមហែកហួរ និង ការបែកបាក់ផ្ទៃក្នុង ឱ្យទៅជាឧបករណ៍ផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈ មានការទទួលខុសត្រូវ មានតម្លាភាព និង ផ្អែកលើវប្បធម៌បម្រើប្រជាជន ទាមទារឱ្យយើងត្រូវអនុវត្តនូវកម្មវិធីកំណែទម្រង់ប្រកបដោយការគិតគូរពិចារណាហ្មត់ចត់ មានជំហានច្បាស់លាស់ និង សមស្របទៅនឹងដំណើរវិវត្តន៍របស់សង្គមកម្ពុជាទាំងមូល ។ ក្នុងន័យនេះ យើងត្រូវធានាថា ការអនុវត្តកំណែទម្រង់ត្រូវតែមានចីរភាព មិនបង្កឱ្យមានការបែកបាក់នៅក្នុងរដ្ឋបាលសាធារណៈ និង ពិសេសជាងនេះទៀត កំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវតែឆ្លើយតបទៅនឹងផលប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជា ។ ក្នុងក្របខ័ណ្ឌនៃទស្សនៈនេះ រាជរដ្ឋាភិបាលកំពុងបន្តអនុវត្តកម្មវិធីកំណែទម្រង់ ដោយប្រកាន់យកនូវភាពជាម្ចាស់ និង ការទទួលខុសត្រូវ ដើម្បីបម្រើផលប្រយោជន៍របស់ជាតិ និង ប្រជាជនកម្ពុជា មិនមែនដើម្បីបំពេញចិត្តអ្នកណាម្នាក់ ហើយក៏មិនមែនសម្រាប់ឆ្លើយតបទៅនឹងនិន្នាការ ឬ របៀបវារៈណាមួយឡើយ ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ការគាំទ្រ និង មតិយោបល់ដ៏ស្មោះត្រង់ និង ក្នុងន័យស្ថាបនារបស់សហគមន៍ដៃគូអភិវឌ្ឍន៍ និង តួអង្គផ្សេងៗទៀត ក្នុងស្មារតីនៃភាពជាដៃគូ ។ យើងដឹងយ៉ាងច្បាស់ថា ប្រវត្តិសាស្ត្រនឹងវិនិច្ឆ័យកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលមួយនេះ ដែលបានកើតចេញពីឆន្ទៈពិតប្រាកដរបស់ប្រជាជនកម្ពុជា តាមរយៈកេរដំណែល និង លទ្ធផលដែលយើងបន្សល់ទុកសម្រាប់ប្រជាជនកម្ពុជា ដែលជាម្ចាស់អំណាចដ៏ពិតប្រាកដ ទាំងក្នុងជំនាន់នេះ និង ជំនាន់ក្រោយៗទៀត ។

**22.** ដោយឡែក ក្នុងក្របខ័ណ្ឌនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កន្លងមកនេះ រាជរដ្ឋា-ភិបាលបានជំរុញ និង សម្រួលធ្វើឱ្យការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ប្រព្រឹត្តទៅបានយ៉ាងរលូនស្របតាមស្មារតីនៃគោលនយោបាយរបស់កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និង កំណែទម្រង់សំខាន់ៗដទៃ

ទៀតរបស់រដ្ឋ ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជាលទ្ធផលជាក់ស្តែង សមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ទាំងអស់ បានសហការគ្នាអនុវត្តការងាររបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរ កាត់បន្ថយបាននូវការរើសអើង និង បែងចែកខាងនយោបាយ ហើយងាកមករកការរួបរួមគ្នា ប្រកបដោយការយោគយល់ និង ការទទួលខុសត្រូវខ្ពស់ ដើម្បីការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនជំនួសវិញ ។ ជាមួយនោះដែរ រាជរដ្ឋាភិបាលបានដាក់ចេញរួចមកហើយនូវក្របខ័ណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រ សម្រាប់ជាត្រីវិស័យចង្អុលផ្លូវនៃការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ រាជរដ្ឋាភិបាលក៏បានអនុម័តផងដែរ នូវកម្មវិធីសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង យូរអង្វែង ដើម្បីឈានទៅសម្រេចចក្ខុវិស័យនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលបានដាក់ចេញ ពោលគឺ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តកាលពីថ្ងៃទី ២៨ ខែ ឧសភា កន្លងទៅ ។ ជាការពិត កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តមិនធ្លាប់ មានក្នុងប្រវត្តិសាស្ត្រ ក្នុងការកែលំអប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិរបស់កម្ពុជា ។ យើងមានឆន្ទៈមោះមុត ឥតរាថយក្នុងការអនុវត្តកំណែទម្រង់នេះ ។ អ្វីដែលជាកត្តាកំណត់ជោគជ័យមួយ ក្នុងចំណោមកត្តាជាច្រើននោះ គឺការចូលរួមពេញលេញពីគ្រប់ភាគីដែលពាក់ព័ន្ធ រួមជាមួយការផ្តល់ការគាំទ្រ ដោយមានការសម្របសម្រួល និង ការគោរពនូវភាពជាម្ចាស់ ដែលអាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកាច់ចង្កូតយានយន្តនៃកំណែទម្រង់នៅលើវិថីថ្មីដ៏លំបាកស្មុគ្រស្មាញនេះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**23.** វិស័យកសិកម្ម គឺជាវិស័យអាទិភាពខ្ពស់បំផុតមួយសម្រាប់ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជាទាំងមូល ។ ក្នុងស្មារតីនេះ គោលនយោបាយកសិកម្មដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ស៊ីសង្វាក់គ្នា និង ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ត្រូវបានរៀបចំឡើង និង បានរម្លេចយ៉ាងច្បាស់ក្នុង **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល ដោយមិនត្រឹមតែសំដៅលើកកម្ពស់វិស័យកសិកម្មឱ្យក្លាយទៅជាផ្នែកមួយនាំមុខ ដែលអាចផ្តល់កម្លាំងចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និង អាចចូលរួមវិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំង ***ធានាឱ្យមានស្បៀងគ្រប់គ្រាន់ និង មានសុវត្ថិភាពសម្រាប់ប្រជាជនគ្រប់រូប ធានាបង្កើនចំណូលសម្រាប់គ្រួសារកសិករ ក៏ដូចជាធានាឱ្យបាននូវការគ្រប់គ្រង និង អភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព*** ផងដែរ ។ ក្នុងន័យនេះ ការអភិវឌ្ឍវិស័យកសិកម្ម គឺជាកូនសោរគន្លឹះក្នុងការទ្រទ្រង់កំណើន និង ក្នុងការធ្វើពិពិធភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ចជាតិ ព្រមទាំងក្នុងការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរបស់ប្រជាជន ។ ជាក់ស្តែង កន្លងមក ទោះបីជាក្នុងកាលៈទេសៈដែលប្រទេសជាតិទទួលនូវផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះកេតសាណា និង បញ្ហានៃសត្វល្អិតបំផ្លាញ ដែលកើតមានឡើងផ្ទួនៗគ្នាយ៉ាងណាក៏ដោយ ប៉ុន្តែ ដោយសារយើងមានគោលនយោបាយត្រឹមត្រូវ និង មានកិច្ចខិតខំប្រឹង-ប្រែងរួមគ្នារវាងរាជរដ្ឋាភិបាល វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ព្រមទាំងកិច្ចខិតខំប្រឹងប្រែងផ្ទាល់ខ្លួនរបស់ប្រជាកសិករ យើងសម្រេចបាននូវសមិទ្ធផលគួរកត់សម្គាល់ក្នុងការលើកកម្ពស់ផលិតភាពកសិកម្ម ពិសេសក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ ដោយបង្កើនបានទាំងគុណភាព និង ទិន្នផល ព្រមទាំងចាប់ផ្តើមលើកស្ទួយ

បានជាបណ្តើរៗនូវសមត្ថភាពកែច្នៃសម្រាប់ការនាំចេញ និង សម្រាប់ប្រើប្រាស់ក្នុងស្រុក ។ ជាមួយគ្នានេះ ចលនានៃការដាំដុះដំណាំផ្សេងៗទៀត ដែលឆ្លើយតបនឹងសេចក្តីត្រូវការនៃទីផ្សារក្នុងតំបន់ និង លើសកលលោក ដូចជា កៅស៊ូ ដំឡូងមី និង ស្វាយចន្ទី ជាដើម ក៏ត្រូវបានពង្រីក និង ជំរុញលើកស្ទួយគួរឱ្យកត់សម្គាល់ ។

**24.** ដោយមើលឃើញថា វិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីនីតិកាលទី ៣ មក រាជរដ្ឋាភិបាលបានដាក់ចេញជាកញ្ចប់គោលនយោបាយ ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ និង ប្រទាក់ក្រឡាគ្នា រួមមាន ការជំរុញបង្កើនផលិតកម្ម និង ពិពិធភាវូបនីយកម្មកសិកម្ម តាមរយៈការបង្កើនគុណភាពដី ការការពារផលដំណាំ ការជ្រើសរើសពូជដែលផ្តល់ទិន្នផលខ្ពស់ ការអនុវត្តយន្តូបនីយកម្ម និង បច្ចេកវិទ្យាទំនើបនៅក្នុងផលិតកម្ម និង ការប្រមូលផល ការពង្រឹងសេវាសំខាន់ៗសម្រាប់គាំទ្រកសិកម្ម ដូចជា ការស្រាវជ្រាវអភិវឌ្ឍន៍ ការផ្សព្វផ្សាយបច្ចេកទេស ការងារសហគមន៍អភិវឌ្ឍន៍កសិកម្ម ការងារសេវាទីផ្សារកសិផល និង ឥណទានជនបទ ការបង្កើនគុណភាពកសិផល ការជំរុញការ-អភិវឌ្ឍកសិ- ឧស្សាហកម្ម និង ការកែច្នៃកសិផល ការជំរុញអនុវត្តកំណែទម្រង់ដីធ្លី ពិសេស គឺការផ្តល់កម្មសិទ្ធិដីធ្លីជូនដល់ប្រជាកសិករ ការបង្កើនចំណាយថវិការដ្ឋទៅលើវិនិយោគសាធារណៈពាក់ព័ន្ធនឹងវិស័យកសិកម្ម ការ-អនុវត្តគោលនយោបាយសារពើពន្ធ ដែលកំណត់អត្រាសូន្យលើពន្ធនាំចូល និង ការដែលរដ្ឋទទួលបន្ទុកពន្ធ និង អាករផ្សេងៗលើវត្ថុធាតុដើមកសិកម្ម មាន ពូជ ជី ថ្នាំសម្លាប់សត្វល្អិត និង សម្ភារៈឧបករណ៍កសិកម្ម ជាដើម ការ-បង្កើតមូលនិធិអភិវឌ្ឍន៍វិស័យកសិកម្ម ការចាត់ចែងរៀបចំនីតិវិធីច្បាប់ដើម្បីដាក់បញ្ចូលគម្រោងវិនិយោគក្នុងវិស័យកសិកម្ម ឱ្យទៅជាគម្រោងអាទិភាពដែលទទួលបានការលើកទឹកចិត្តខ្ពស់ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីវិនិយោគជាធរមាន និង ការជំរុញឱ្យមានភាពជាដៃគូរវាងកសិករម្ចាស់ដីតូចៗ និង កសិដ្ឋានខ្នាតធំ និង សាជីវកម្មកសិកម្ម ព្រមទាំងជំរុញការបង្កើតសហគមន៍កសិករ ក៏ដូចជាការជំរុញឱ្យមានភាពជាដៃគូរវាងសហគមន៍កសិករជាមួយក្រុមហ៊ុនប្រមូលទិញ កែច្នៃ ចែកចាយ និង នាំចេញផលិតផលស្រូវ- អង្ករផងដែរ ។ល។

**25.** កម្ពុជាមាន ***«មាសស»*** នៅលើដី នោះគឺអង្កររបស់យើង ដែលមានគុណភាពសមស្របទៅនឹងសេចក្តី-ត្រូវការរបស់ទីផ្សារពិភពលោក ដែលកំពុងតែមានការកើនឡើង ។ បច្ចុប្បន្ន បន្ទាប់ពីការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក យើងមានស្រូវដែលលើសពីតម្រូវការដល់ទៅជាង ៣ លានតោន បើគិតជាអង្ករស្មើនឹងជាង ២ លានតោន ។ ចំពោះការផ្គត់ផ្គង់វិញ ប្រទេសដែលបច្ចុប្បន្នធ្វើការនាំចេញអង្ករ ពុំមានលទ្ធភាពច្រើនប៉ុន្មានទេ ក្នុងការជំរុញបង្កើនផលិតផលរបស់ខ្លួន ។ ចំណែកកម្ពុជានៅមានលទ្ធភាពដ៏ធំធេង ដើម្បីបង្កើនផលិតកម្ម និង ផលិតភាព តាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រដើម្បីស្រោចស្រព ការជ្រើសរើសពូជ ការប្រើប្រាស់ជី និង ការប្រើប្រាស់បច្ចេកទេសទំនើប ។ រាជរដ្ឋាភិបាលបានមើលឃើញយ៉ាងច្បាស់នូវកាលានុវត្តនៃការជំរុញនាំចេញអង្ករ ដែលជា ***«មាសស»*** របស់កម្ពុជា នៅក្នុងបរិការណ៍នៃការកើនឡើងនៃតម្រូវការនៅលើទីផ្សារសកលលោក និង សក្តានុពលដ៏ធំធេងក្នុងការផលិតដែលកម្ពុជានៅមាននេះ ។ យើងក៏មានការយល់ដឹងយ៉ាងច្បាស់ដែរថា វិធានការទាំងឡាយដែលយើងបានដាក់ចេញមកហើយនេះ ថ្វីត្បិតថាមានសារៈសំខាន់មិនអាចខ្វះបាន តែអាចនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដើម្បីក្តាប់យកមកប្រើប្រាស់ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ក្នុងពេលចំពោះមុខ នូវកាលា-នុវត្តភាពដ៏កម្រនេះ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញក្នុងរយៈពេលដ៏ខ្លីខាងមុខ នូវឯកសារគោល-

នយោបាយមួយ ***«ស្តីពីវិធានការជំរុញការផលិតស្រូវ និង ការនាំចេញអង្ករ»*** ។ ដូច្នេះ ខ្ញុំអំពាវនាវស្នើសុំឱ្យដៃគូដែលមានការពាក់ព័ន្ធទាំងអស់ ពិសេសដៃគូវិស័យឯកជន មេត្តាចូលរួមផ្តល់នូវការគាំទ្រចាំបាច់គ្រប់បែបយ៉ាង ដល់ការជំរុញអនុវត្តវិធានការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាប្រយោជន៍ដល់ការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជន និង ការអភិវឌ្ឍកម្ពុជាប្រកបដោយចិរភាព ។

**26.** ដូចអស់លោកអ្នកទាំងអស់គ្នាបានជ្រាបស្រាប់ហើយ យុទ្ធសាស្រ្តសម្រាប់វិស័យកសិកម្ម និង ការផ្គត់ផ្គង់ទឹក ត្រូវបានរៀបចំកសាងរួចជាស្រេច ដោយមានការចូលរួមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងធនធានទឹក និង ឧតុនិយម និង គ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងវិស័យកសិកម្ម និង ធនធានទឹក ។ យុទ្ធ-សាស្រ្តនេះ បានតម្រង់ទិសដៅរបស់ខ្លួនទៅរកការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្សារភ្ជាប់នឹងទឹក ដែលរួមមានកម្មវិធីចំនួន ៥ គឺ: ***(១).*** កម្មវិធីគាំទ្រដល់ការពង្រឹងសមត្ថភាព និង គ្រប់គ្រងស្ថាប័ននៅក្នុងវិស័យកសិកម្ម និង ទឹក ***(២).*** កម្មវិធីគាំទ្រសន្តិសុខស្បៀង ***(៣).*** កម្មវិធីគាំទ្រកសិកម្ម និងកសិ- ពាណិជ្ជកម្ម ***(៤).*** កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រព និង ដីធ្លី និង ***(៥).*** កម្មវិធីស្រាវជ្រាវ អប់រំ និង ផ្សព្វផ្សាយសម្រាប់កសិកម្ម និង ធនធានទឹក ។ ចំពោះមុខ រាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពខ្ពស់ដល់ការជំរុញអនុវត្តគោលនយោបាយវិត្ថារកម្មប្រព័ន្ធធារាសាស្រ្ត ដើម្បីពង្រីកផ្ទៃដីដាំដុះ និង បង្កើនផលិតភាពដី ដោយផ្តោតការយកចិត្តទុកដាក់បន្ថែម លើការរៀបចំបណ្តាញស្រោចស្រពភ្ជាប់ពីប្រព័ន្ធធារាសាស្រ្តធំៗ ឱ្យចូលដល់ស្រែរបស់ប្រជាជន និងលើការរៀបចំយន្តការចូលរួមរបស់ប្រជាជន ក្នុងការគ្រប់គ្រង និង ថែទាំបណ្តាញធារាសាស្រ្តខ្នាតតូចទាំងនេះ ។ ច្បាស់ណាស់ថា តំបន់ក្រីក្រខ្លាំង និង តំបន់ដែលមានសក្តានុពលកសិកម្មធំ ពិសេសសក្តានុពលដំណាំស្រូវ គឺជាអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។

**27.** ជាមួយគ្នានេះ កំណែទម្រង់ព្រៃឈើ កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង កំណែទម្រង់ជលផល នឹងនៅតែត្រូវបានបន្តជំរុញអនុវត្តយ៉ាងសកម្ម ក្នុងគោលបំណងរក្សាប្រសិទ្ធភាពនៃការ-គ្រប់គ្រង និង ការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយចីរភាព ។ ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានប្រកាន់យកនូវអភិក្រមភ្លៀងរលឹម និង ការចាត់វិធានការដោះស្រាយដល់ឫសគល់ ក្នុងការបង្ក្រាបបទល្មើសព្រៃឈើ និង ការធ្វើអាជីវកម្មឈើខុសច្បាប់ ។ រាជរដ្ឋាភិបាលបន្តប្រកាន់ជំហរហ្មឹងម៉ាត់ក្នុងការងារគ្រប់គ្រងដីធ្លី ដោយបន្តបង្ក្រាបបទល្មើសរំលោភយកដីរដ្ឋ, បន្តបដិសេធចោលរាល់ទម្រង់នៃកម្មសិទ្ធិដែលចេញដោយគ្មាននីតិវិធីច្បាស់លាស់, បន្តយកចិត្តទុកដាក់ដល់ការងារសម្បទានដីសង្គមកិច្ចឱ្យប្រកបដោយផលិតភាពខ្ពស់ និង ធានាបានប្រសិទ្ធភាពសេដ្ឋកិច្ច ដើម្បីជួយដល់ប្រជាជនដែលគ្មានដី និង ត្រូវការដីពិតប្រាកដ, បន្តការដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចទាំងឡាយ ដែលសម្បទានិកមិនបានអនុវត្តការងារឱ្យបានពេញលេញតាមកាតព្វកិច្ចក្នុងកិច្ចសន្យា និង បន្តអនុវត្តឱ្យកាន់តែពេញលេញ ហ្មត់ចត់ និង ស៊ីជម្រៅនៃគោលនយោបាយស្បែកខ្លា និង គោលនយោបាយបម្រុងទុកដីធ្លីសម្រាប់សម្បទានដីសង្គមកិច្ចក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចនោះ ។ ច្បាស់ណាស់ថា វិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និង ប្រើប្រាស់ដីធ្លី ព្រមទាំងវិធានការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី នឹងនៅបន្តជាអាទិភាពខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងការបន្តខិតខំលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និង មិន

ផលិត ។ ផ្អែកលើលទ្ធផលទាំងអស់ដែលសម្រេចបានក្នុងរយៈពេលកន្លងមកនេះ រាជរដ្ឋាភិបាលនឹងរៀបចំនូវគោលនយោបាយដីធ្លីពេញលេញមួយ ដែលមានលក្ខណៈជា ***«សៀវភៅស»*** សម្រាប់ជាផែនទីចង្អុលផ្លូវលើការងារកែទម្រង់ដីធ្លី នៅក្នុងរយៈពេលមធ្យម និង រយៈពេលវែងខាងមុខ ។

**28.** ជាប់ពាក់ព័ន្ធនឹងនេះដែរ ការបោសសម្អាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក៏នៅតែបន្តស្ថិតជាអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសនៅតំបន់ដាច់ស្រយាល តំបន់ដែលកសិករខ្វះដី និង តំបន់មានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍកសិកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ ។ សកម្មភាពដោះមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវតែផ្សារភ្ជាប់ទៅនឹងគោលការណ៍បែងចែកដីសម្អាតរួចហើយនេះ ឱ្យប្រជាកសិករដែលខ្វះដីពិតប្រាកដ ប្រកបដោយសមធម៌ ។ ចំពោះការគ្រប់គ្រងធនធានជលផល ក៏ត្រូវបានបន្តពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ជាមួយនឹងការអនុវត្តខ្ជាប់ខ្ជួននូវវិធានការមុតស្រួច ដើម្បីការពារធនធានធម្មជាតិទាំងអស់នេះ ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តវិធានការច្បាប់ដោយចាប់បញ្ជូនទៅកាន់តុលាការ នូវជនល្មើសទាំងឡាយណាដែលមិនព្រមរៀងចាល និង ប្រព្រឹត្តនូវបទល្មើសដែលធ្វើឱ្យខូចអន្តរាយដល់ធនធានជលផល សត្វព្រៃ និង ព្រៃឈើរបស់ព្រះរាជាណាចក្រកម្ពុជា ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**29.** ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលយល់ច្បាស់ថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន ដើម្បីធានាជំរុញការអភិវឌ្ឍប្រទេសជាតិ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពិសេស តាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង ការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវ ***«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»*** ដំណាក់កាលទី ២ ដោយឈរលើមូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបាន ដែលជាសមិទ្ធផលនៅដំណាក់កាលទី ១ និង ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើងក្នុងដំណាក់កាលទី ២ ដែលជាដំណាក់កាលគន្លឹះនៃកម្មវិធីកែទម្រង់ទាំងមូល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួនបំផុតនូវបទវិន័យ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ ក្នុងនេះ ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវបានផ្តោតទៅលើការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការប្រមូល និង គ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព នូវចំណូលពីអាជីវកម្មលើធនធានរ៉ែគ្រប់ប្រភេទ ពិសេសរ៉ែមាស និង ធនធានប្រេង និង ឧស្ម័នរបស់ជាតិ ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលនឹងនៅតែបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់នូវ ***«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥»*** ជាពិសេសការជំរុញការបង្កើតទីផ្សារមូលប័ត្រកម្ពុជា ដែលនឹងក្លាយទៅយន្តការមួយដ៏សំខាន់សម្រាប់កៀរគធនធានហិរញ្ញវត្ថុ ពីក្នុង និង ក្រៅប្រទេស យកមកចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**30.** ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍវិស័យឯកជន រាជរដ្ឋាភិបាលបាន និង កំពុងបន្តជំរុញការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗ និង បានបង្កើតនូវបរិស្ថានសមស្រប ដែលធានានូវស្ថិរភាព និង ភាពអាចប៉ាន់ប្រមាណបាន ដើម្បីទាក់ទាញ និង លើកស្ទួយវិនិយោគឯកជន ។ ក្នុងនោះ ផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវលំជា

ច្រើនពាន់គីឡូម៉ែត្រ ត្រូវបានស្ថាបនាឡើង ដើម្បីតភ្ជាប់ជាបណ្ដាញសសៃឈាមសេដ្ឋកិច្ច និង ធ្វើសមាហរណកម្មផ្ទៃក្នុងកម្ពុជា ក្នុងគោលបំណងផ្ដល់លទ្ធភាពកាន់តែខ្ពស់ដល់សកម្មភាពសេដ្ឋកិច្ច និង ជំរុញការបែងចែកផ្លែផ្កានៃកំណើនឱ្យបានទូលំទូលាយពាសពេញផ្ទៃប្រទេស ក៏ដូចជាភ្ជាប់កម្ពុជាទៅនឹងចរន្តសេដ្ឋកិច្ច ពាណិជ្ជកម្ម និង គមនាគមន៍តំបន់ និង ពិភពលោក ។ ក្នុងន័យនេះ ការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ នឹងនៅតែបន្តស្ថិតនៅជាអទិភាពដ៏ចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ។

**31.** ជាការពិតណាស់ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយបន្តធានានូវបរិស្ថានធុរកិច្ចមួយ ដែលកាន់តែល្អប្រសើរដើម្បីបង្កើនសក្ដានុពលនៃវិស័យឯកជនក្នុងការចូលរួមអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ចជាតិ ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការកែលម្អយន្តការស្ថាប័ន ក្របខ័ណ្ឌគតិយុត្ត និង និយ័តកម្ម សម្រាប់ការរីកលូតលាស់នៃវិស័យឯកជន ដោយបន្តធ្វើឱ្យកាន់តែប្រសើរនូវការសម្រួលពាណិជ្ជកម្ម និង វិនិយោគ កាត់បន្ថយតម្រូវការក្នុងការសុំអាជ្ញាប័ណ្ណផ្សេងៗ បំព្រួញបែបបទអន្តរស្ថាប័ន កាត់បន្ថយចំណាយក្រៅផ្លូវការក្នុងការបំពេញបែបបទរដ្ឋបាល និង ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តិ និង យន្តការស្ថាប័ន សម្រាប់អភិវឌ្ឍន៍ និង គ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។ល។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការវេទិការាជរដ្ឋាភិបាល និងវិស័យឯកជន ដែលវេទិកានេះបានក្លាយជាយន្តការដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហា ដែលជាកង្វល់រួមរបស់រាជរដ្ឋាភិបាល និង វិស័យឯកជននោះ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលសូមស្វាគមន៍វិភាគទានដ៏មានសារៈសំខាន់របស់ដៃគូអភិវឌ្ឍន៍ ដែលមានឆន្ទៈ និង បានផ្ដល់ការគាំទ្រដល់កម្ពុជាក្នុងការជំរុញការអភិវឌ្ឍវិស័យឯកជន ដូចជាតាមរយៈការចូលរួមក្នុងកិច្ចដំណើរការនៃវេទិការាជរដ្ឋាភិបាលវិស័យឯកជន និង តាមរយៈការគាំទ្រជាធនធាន និង បច្ចេកទេសផ្សេងៗទៀត ។ ជាចក្ខុវិស័យវែងឆ្ងាយ រាជរដ្ឋាភិបាលចង់ឃើញ ***«វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា»*** នេះ មានការវិវត្តន៍ប្រែក្លាយទៅជា ***«វេទិកាអភិវឌ្ឍន៍កម្ពុជា»*** ដែលក្នុងនោះគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់របស់រាជរដ្ឋាភិបាល ទាំងដៃគូសហប្រតិបត្តិការផ្លូវការ ទាំងដៃគូវិស័យឯកជន និង ដៃគូសង្គមស៊ីវិល រួមគ្នានៅក្នុងសាលប្រជុំតែមួយជាមួយនឹងរាជរដ្ឋាភិបាល ពិភាក្សាលើរបៀបវារៈនៃការអភិវឌ្ឍន៍កម្ពុជា ហើយសម្របសម្រួលការចូលរួមវិភាគទានរបស់ខ្លួន ដើម្បីធ្វើឱ្យបានសម្រេចនូវរបៀបវារៈនៃការអភិវឌ្ឍនេះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**32.** រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់ក្នុងវិស័យអប់រំ ពិសេសការសម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦- ២០១០ ដែលជាផ្នែកមួយនៃ ***យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២*** របស់រាជរដ្ឋាភិបាល ហើយដែលបានផ្ដោតការយកចិត្តទុកដាក់ទៅលើការធានាឱ្យបានថា កុមារ និង យុវជនកម្ពុជាទាំងអស់គ្នា មានកាលានុវត្តភាពស្មើៗគ្នា ក្នុងការទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និង ឋានៈសង្គម ។ លើមូលដ្ឋាននៃទស្សនវិជ្ជានេះ រាជរដ្ឋាភិបាលនឹងបន្តផ្ដល់អាទិភាពដល់ការធានាសមធម៌ ក្នុងការអប់រំមូលដ្ឋាន រយៈពេល ៩ ឆ្នាំ សម្រាប់កុមារគ្រប់រូប ស្របតាមគោលការណ៍ ***«ការអប់រំ គឺសម្រាប់ទាំងអស់គ្នា ហើយទាំងអស់គ្នាគឺសម្រាប់ការអប់រំ»*** ។ ពិតណាស់ថា ក្នុងបណ្ដាឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលតែងបានយកចិត្តទុកដាក់ដោះស្រាយ

បញ្ហាប្រឈមចំពោះមុខនានា សំដៅបន្តរៀបចំ និង អនុវត្តផែនការថ្មីឱ្យប្រកបដោយសង្គតិភាព ជាមួយគោលដៅនៃវិស័យអប់រំ និង សំដៅលើកកម្ពស់ការចូលរួមឱ្យកាន់តែសកម្មខ្លាំងក្លាពីគ្រប់ក្រសួង- ស្ថាប័ន ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និង សង្គមស៊ីវិល ដើម្បីធានាឱ្យបាននូវសមធម៌នៃការចូលរៀន និង ការបន្តលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពអប់រំនៅគ្រប់ភូមិសិក្សា ដែលប្រការនេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតឡើងនូវផ្លែផ្កា និង ភាពរីកចម្រើនរុងរឿងសម្រាប់សង្គមជាតិកម្ពុជា ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកំពុងតែបន្តផ្តោតការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្រិតឧត្តមសិក្សា និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយធានាឱ្យប្រាកដថា គ្រប់គ្រឹះស្ថានឧត្តមសិក្សា និង បណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់ការអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាព ដែលអាចប្រកួតប្រជែងបាននៅក្នុងទីផ្សារការងារ ទាំងនៅក្នុងស្រុក និង ក្រៅប្រទេស តាមរយៈការបន្តផ្តល់អាទិភាពនៃចំណាយថវិកាជាតិសម្រាប់វិស័យនេះ លើការបង្កើនចំនួនអាហារូបករណ៍ និង ការកសាងអន្តេវាសិកដ្ឋាន សាលារៀន និង ការពង្រាយគ្រូឱ្យចំគោលដៅនៅទូទាំងប្រទេស ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងបន្តកៀរគការចូលរួមរបស់វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល ដើម្បីបន្តលើកកម្ពស់វិស័យអប់រំនៅគ្រប់កម្រិតភូមិសិក្សា និង កម្រិតគុណភាពជំនាញវិជ្ជាជីវៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋានសម្ភារៈបរិក្ខារសាលារៀន ឱ្យបានកាន់តែមានលក្ខណៈទំនើប មានគុណភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការរៀនសូត្រ និង ប្រសិទ្ធភាពការងារ ។

**33.** ក្នុងវិស័យសុខាភិបាល កម្ពុជាក៏សម្រេចបាននូវវឌ្ឍនភាពមួយគួរឱ្យកត់សម្គាល់ផងដែរ លើការងារស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និង ស្ថាប័ន ដែលជាមូលដ្ឋានគ្រឹះក្នុងការគាំទ្រ និង ការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្តល់សេវាសុខភាព ដើម្បីឆ្លើយតបបានទាន់ពេលវេលាទៅនឹងតម្រូវការថែទាំសុខភាពជាសារវ័ន្តរបស់ប្រជាជននៅទូទាំងប្រទេស ។ ពិតណាស់ថា រាជរដ្ឋាភិបាលនៅតែបន្តផ្តល់អាទិភាពខ្ពស់ទៅលើការការពារ និងទប់ស្កាត់ទាន់ពេលវេលានូវជម្ងឺរាតត្បាតផ្សេងៗ ការថែរក្សាសុខភាព អនាម័យ និង ការផ្តល់អាហារូបត្ថម្ភដល់ប្រជាពលរដ្ឋ ។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ យើងបានកំណត់យ៉ាងច្បាស់ថា ប្រជាពលរដ្ឋមានសុខភាពល្អ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចប្រកបដោយចីរភាព ។ ជាក់ស្តែង កម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរកត់សម្គាល់ ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយអត្រាមរណៈរបស់មាតា និង ទារក ដោយបានដាក់ពង្រាយឆ្មប ឱ្យបានយ៉ាងហោចមួយរូប នៅតាមមណ្ឌលសុខភាពនៅទូទាំងប្រទេស ។ ការទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺអេដស៍ ក៏សម្រេចបានជាលទ្ធផលជាផ្លែផ្កា ដោយក្នុងនោះអត្រាឆ្លងជំងឺដ៏កាចសាហាវនេះ ត្រូវបានធ្វើស្ថិរភាវូបនីយកម្មនៅត្រឹម ០,៩% ។ ជាមួយនេះ រាជរដ្ឋាភិបាលកំពុងតែបន្តជំរុញអនុវត្តផែនការអភិវឌ្ឍន៍វិស័យសុខាភិបាល ២០០៨- ២០១៥ ដើម្បីពង្រឹងការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពជូនដល់ប្រជាជន ការកែលម្អឥរិយាបថរបស់អ្នកផ្តល់សេវាសុខាភិបាល ការធានានូវលំហូរមូលធនសម្រាប់ផ្គត់ផ្គង់គ្រឿងបរិក្ខារពេទ្យឱ្យបានគ្រប់គ្រាន់ និង ទៀងទាត់ ការពង្រឹងជំនាញ និង សមត្ថភាពរបស់បុគ្គលិក ការកែលម្អការផ្គត់ផ្គង់ឱសថ និង ការពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល ការផ្តល់សេវាហិរញ្ញប្បទានសុខាភិបាល និង អភិបាលកិច្ចសុខាភិបាល ។ល។ កិច្ចការទាំងអស់នេះ នឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសុខភាពជូនបងប្អូនប្រជាជន រួមចំណែកបង្កើតជាសំណាញ់សុវត្ថិភាពសង្គមមួយដ៏មានប្រសិទ្ធភាព នៅ

ក្នុងបុព្វហេតុនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញ និង អនុវត្តឱ្យបានសកម្មខ្លាំងក្លានូវវាលវិធានការ និង រាល់គោលនយោបាយគន្លឹះនានា ទាំងការលើកស្ទួយភាពជាដៃគូ ទាំងការងារកំណែទម្រង់វិស័យនេះ សំដៅបន្តលើកកម្ពស់បរិស្ថានវិនិយោគរបស់វិស័យឯកជន ការកៀរគរការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តលើវិស័យនេះ ដែលនឹងបង្កើតជាយន្តការគន្លឹះសម្រាប់អភិវឌ្ឍវិស័យសុខាភិបាលកម្ពុជាឱ្យបានកាន់តែឆាប់រហ័ស ។

**34.** រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងលើកស្ទួយឋានៈរបស់ស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិ តាមរយៈ ការបន្តអនុវត្តផែនការយុទ្ធសាស្ត្រ ***«នារីរតនៈទី ៣»*** ក្នុងគោលបំណងផ្តល់ជូនស្ត្រីខ្មែរ នូវតម្លៃ និង ក្តីសង្ឃឹមក្នុងជីវិត ។ រាជរដ្ឋាភិបាលតែងផ្តល់អាទិភាពខ្ពស់ទៅលើការលើកកម្ពស់តម្លៃ តួនាទី និង ស្ថានភាពសង្គមរបស់ស្ត្រី តាមរយៈការជំរុញការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ដែលផ្តោតលើការកសាងសមត្ថភាពរបស់ស្ត្រី ការលើកកម្ពស់លទ្ធភាពរបស់ស្ត្រីក្នុងវិស័យអប់រំ សុខាភិបាល និង ធនធានសេដ្ឋកិច្ច ការផ្លាស់ប្តូរឥរិយាបថអវិជ្ជមាននៃសង្គមចំពោះស្ត្រី និង ការបង្កើនការចូលរួមរបស់ស្ត្រីក្នុងគ្រប់កិច្ចការសាធារណៈ ព្រមទាំងការធានាអំពីសិទ្ធិ ដើម្បីឱ្យស្ត្រីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្ម និង ដោយស្មើភាព ក្នុងដំណើរការកសាងប្រទេសជាតិ ។ ពិតណាស់ថា ការទប់ស្កាត់ និង លុបបំបាត់អំពើហិង្សានៅក្នុងគ្រួសារ ការជួញដូរស្ត្រី និង អាជីវកម្មលើកុមារ ត្រូវតែដើរស្របគ្នានឹងការងារប្រយុទ្ធប្រឆាំង និង ការលុបបំបាត់ការផលិត ជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន ដែលជាបញ្ហាដ៏ស្រួចស្រាវមួយរបស់សង្គម ហើយបង្កផលប៉ះពាល់ដល់សុខុមាលភាពរបស់យុវជនកម្ពុជា ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់ឱ្យកាន់តែសកម្មខ្លាំងក្លាឡើងថែមទៀត និង ចាត់វាលវិធានការចាំបាច់នានា ដើម្បីឈានទៅលុបបំបាត់ និង ទប់ស្កាត់ឱ្យមានប្រសិទ្ធភាពខ្ពស់នូវបាតុភាពអសកម្មទាំងអស់នេះ ។ ជាការពិត ជោគជ័យលើការងារនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន និង ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចជារួមផងដែរ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**35.** វិបត្តិសេដ្ឋកិច្ចសកលលោកក្នុងឆ្នាំកន្លងមក បានក្លាយជាវិញ្ញាសាមួយដ៏លំបាក និង ជាការសាកល្បងមួយដ៏ធំ សម្រាប់វាស់ស្ទង់ភាពរឹងមាំនៃសមិទ្ធផលជាផ្លែផ្កាដែលយើងសម្រេចបានក្នុងរយៈពេលកន្លងមក និង សម្រាប់វាស់ស្ទង់សមត្ថភាពដឹកនាំរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច ។ ក្នុងដំណើរឆ្លងកាត់ដំណាក់កាលដ៏លំបាកបំផុតនៃវិបត្តិកន្លងមកនេះ កម្ពុជាប្រមូលផ្តុំបាននូវមេរៀន និងបទពិសោធន៍ជាច្រើន តាមរយៈការដាក់ចេញ និង ការជំរុញអនុវត្តគោលនយោបាយដ៏ចាំបាច់នានា ដើម្បីឆ្លើយតបទៅនឹងវិបត្តិ ពិសេសគឺការដាក់ចេញនូវវិធានការជាប្រព័ន្ធ ស៊ីសង្វាក់ និង ប្រទាក់ក្រឡាគ្នា សំដៅជួយស្រោចស្រង់វិស័យដែលទទួលរងផលប៉ះពាល់អាក្រក់ដោយផ្ទាល់ពីវិបត្តិ ដែលគួបផ្សំជាមួយនឹងការពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ប្រជាពលរដ្ឋកម្ពុជា និង ការផ្តោតអាទិភាពទៅលើវិស័យដែលមានសក្តានុពលកំណើនខ្ពស់ ហើយអាចចូលរួមចំណែកយ៉ាងសំខាន់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីពិពិធភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ច និង ដើម្បីការកាត់បន្ថយភាពក្រីក្រ និង ការកែលម្អជីវភាពប្រជាជនកម្ពុជាភាគច្រើនលើសលប់ដែលរស់នៅតាមទីជនបទ ពោលគឺវិស័យកសិកម្ម ។ ឈានចេញពី

មេរៀន និង បទពិសោធន៍ទាំងនេះ យើងបានមើលឃើញអំពីសេចក្តីត្រូវការក្នុងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈគត់មត់ គ្រប់ជ្រុងជ្រោយ និង សមស្របទៅតាមសមត្ថភាព និង សេចក្តីត្រូវការរបស់កម្ពុជា ។ បច្ចុប្បន្ន ក្របខ័ណ្ឌទស្សនាទាននៃប្រព័ន្ធសុវត្ថិភាពសង្គមនេះ ត្រូវបានរៀបចំរួចស្រេចបាច់ហើយ ហើយយើងកំពុងតែរៀបចំបោះជំហានទៅមុខថែមទៀត ដើម្បីប្រែក្លាយប្រកខ័ណ្ឌទស្សនាទាននេះ ឱ្យទៅជាយន្តការជាក់ស្តែងសម្រាប់ការអនុវត្ត ។

**36.** លើមូលដ្ឋាននៃបទពិសោធន៍ដែលយើងមាន និង មេរៀនដែលយើងដកស្រង់បានមកនេះ យើងក៏ដឹងយ៉ាងច្បាស់ដែរថា ខណៈនេះ នៅពេលដែលព្យុះនៃវិបត្តិសកលបានថមថយចុះមកវិញ យើងត្រូវតែសម្លឹងទៅមុខ ដើម្បីកំណត់នូវបណ្តាវិធានការគោលនយោបាយចាំបាច់ទាំងឡាយ ដែលយើងត្រូវជំរុញអនុវត្ត សំដៅធានាដាក់កម្ពុជាឱ្យស្ថិតនៅលើគន្លងនៃកំណើនសេដ្ឋកិច្ចខ្ពស់ជាថ្មី ហើយបន្តពង្រឹង និង ពង្រីកសមិទ្ធផលទាំងឡាយរបស់យើង ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលនៅក្នុងដំណើរឆ្ពោះទៅមុខនេះ យើងត្រូវធានាឱ្យបានផងដែរថា រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា នឹងត្រូវបានធ្វើទំនើបកម្ម ហើយមូលដ្ឋាននៃកំណើនសេដ្ឋ-កិច្ច នឹងត្រូវបានពង្រីកឱ្យទូលំទូលាយជាងមុន ជាមួយនឹងភាពជឿនលឿននៃសមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុងប្រទេស និង ទៅក្នុងតំបន់ ។ ដូច្នេះ បញ្ហាគន្លឹះរបស់យើង គឺការលើកស្ទួយ ***«សមត្ថភាពប្រកួតប្រជែង»*** របស់ខ្លួន ។ ខ្ញុំពឹងថា អាទិភាពចម្បងៗ ដែលខ្ញុំបានគូសបញ្ជាក់ពីខាងលើ រួមជាមួយនឹងវិធានការគោលនយោបាយលម្អិតផ្សេងទៀត ដែលមានចែងនៅក្នុង ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម*** នឹងជួយត្រួសត្រាយផ្លូវដឹកនាំនាវាកម្ពុជា ឱ្យបន្តដំណើរទៅមុខទៀត ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ និង គោលដៅជាយុទ្ធសាស្ត្រប្រកបដោយមហិច្ឆិតា ដែលរាជរដ្ឋាភិបាលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២** ។

**37.** គ្មានការសង្ស័យទេថា ក្នុងដំណាក់កាលបច្ចុប្បន្ននេះ ធនធានសហប្រតិបត្តិការដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ នឹងនៅតែមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ដោយយោងលើសារៈសំខាន់នេះ កម្ពុជាមានការប្តេជ្ញាខ្ពស់ក្នុងការប្រើប្រាស់ធនធានសហប្រតិបត្តិការទាំងអស់នោះ ឱ្យបានប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិបំផុត ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំពិតប្រាកដសម្រាប់ជំរុញកំណើន និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ដៃគូពាក់ព័ន្ធទាំងឡាយ ទាំងដៃគូអភិវឌ្ឍន៍ផ្លូវការ ទាំងដៃគូវិស័យឯកជន និង ទាំងដៃគូសង្គមស៊ីវិល ដែលតែងបានសហការ និង ជួយផ្តល់នូវការឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងដល់រាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា នៅក្នុងរយៈពេលកន្លងទៅនេះ ។ ដោយឡែក ខ្ញុំសង្ឃឹមថា អង្គប្រជុំរបស់យើងក្នុងរយៈពេលពីរថ្ងៃនេះ នឹងផ្តល់ពេលវេលាសមរម្យសម្រាប់ពិភាក្សាលើសមិទ្ធផល ក៏ដូចជាការខ្វះខាត និង បញ្ហាប្រឈមទាំងឡាយ ដែលយើងទាំងអស់គ្នាកំពុងជួបប្រទះ ដើម្បីរិះរកវិធីបង្កើនល្បឿននៃដំណើរទៅមុខរបស់កម្ពុជា ឆ្ពោះទៅរកវឌ្ឍនភាព និង វិបុលភាពទ្វេឡើង ។ ក្នុងន័យនេះ ខ្ញុំមានជំនឿថា កម្ពុជាពិតជាអាចបន្តបោះជំហានទៅមុខ ដើម្បីសម្រេចនូវចក្ខុវិស័យវែងឆ្ងាយរបស់ខ្លួនពោល គឺការកសាងជាជំហានៗនូវសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, មានការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរី ពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, មានកោសិកាផ្សារភ្ជាប់គ្នា,

មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និង វប្បធម៌ជ្រៅជ្រះ, មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ។

**38.** ក្នុងបរិការណ៍នេះ ច្បាស់ណាស់ថា **«ភាពជាដៃគូ»** ដែលឈរលើមូលដ្ឋាននៃកិច្ចសហការ ភាពស្មោះត្រង់ ការទុកចិត្តគ្នា ការទទួលខុសត្រូវទៅវិញទៅមក និង ការគោរពភាពជាម្ចាស់ នឹងក្លាយទៅជាកត្តាកំណត់ដ៏សំខាន់បំផុតមួយ នៅក្នុងកិច្ចប្រឹងប្រែងរបស់យើងទាំងអស់គ្នា ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២** ។ ក្នុងស្មារតីនេះ ខ្ញុំសូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះការបន្តពង្រឹងភាពជាដៃគូ តាមរយៈការអនុវត្តការងាររួមគ្នាលើវិធីសាស្ត្រវាយតម្លៃដោយផ្អែកលើលទ្ធផលការងារ ដែលជាយន្តការជួយបង្កើនប្រសិទ្ធភាពការងារ ពង្រឹងភាពជាម្ចាស់ និង ពង្រឹងប្រព័ន្ធគ្រប់គ្រងលើគ្រប់វិស័យ ព្រមទាំងជួយឱ្យគ្រប់គ្រងបាននូវរាល់ទម្រង់នៃធនធានអភិវឌ្ឍន៍ និង ជួយធានាដល់ការទទួលខុសត្រូវទៅវិញទៅមកលើលទ្ធផលការងារដែលសម្រេចបាន ។ តាមរយៈនេះ កម្ពុជាសូមស្វាគមន៍ចំពោះ **យន្តការត្រួតពិនិត្យរួមគ្នាលើសូចនាករអភិវឌ្ឍន៍** និង **វិធីសាស្ត្រវាយតម្លៃការងារដោយផ្អែកលើលទ្ធផល** ដែលនឹងផ្ដល់លទ្ធភាពខ្ពស់សម្រាប់ការតាមដានអំពីវឌ្ឍនភាពនានា ដូចបានលើកឡើងក្នុងវេទិកានេះ និង សម្រាប់វេទិកាក្រោយៗទៀត ។ ក្នុងន័យនេះ ខ្ញុំសូមស្នើដល់គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានអភិវឌ្ឍន៍ទាំងអស់ ត្រូវរួមចំណែកឱ្យបានសកម្មខ្លាំងក្លា និង ផ្ដល់កិច្ចសហការឱ្យបានស្អិតរមួត រួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលទាំងអស់ ដើម្បីធ្វើឱ្យប្រាកដថា ធនធានអភិវឌ្ឍន៍ទាំងអស់នោះ ត្រូវបានប្រើប្រាស់ចំទិសដៅ និង ផ្ដល់ផលប្រយោជន៍យ៉ាងពិតប្រាកដដល់ប្រជាជន និង សង្គមជាតិ ។ ជាមួយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ចំពោះឯកឧត្តម ***ឈៀង យ៉ាណារ៉ា*** ដែលបានដឹកនាំការរៀបចំ ***«របាយការណ៍ស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា»*** ដោយបានវាយតម្លៃពីសមិទ្ធផលដែលយើងសម្រេចបាន ក៏ដូចជាបានរម្លេចឱ្យឃើញយ៉ាងច្បាស់ពីបញ្ហាប្រឈមដែលកម្ពុជាកំពុងជួបប្រទះ ក្នុងការប្រើប្រាស់ធនធានដើម្បីសម្រេចកិច្ចអភិវឌ្ឍដោយផ្ដោតលើលទ្ធផល និង ការត្រៀមរៀបចំនានា ទាំងខាងបច្ចេកទេស ទាំងផ្នែកប្រព័ន្ធផ្ដល់ការសម្រួលសម្រាប់ដំណើរការវេទិកាលើកនេះ ។

**39.** ខ្ញុំពិតជាមានសេចក្ដីរីករាយ ដោយសង្កេតឃើញដៃគូរបស់យើងជាច្រើន បានចូលរួមក្នុងវេទិកាថ្ងៃនេះ ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ និង វាយតម្លៃខ្ពស់ចំពោះទស្សនៈដ៏សម្បូណ៌បែបស្ដីពីកិច្ចអភិវឌ្ឍដែលដៃគូរបស់យើងអាចផ្ដល់ជាវិភាគទានដល់កម្ពុជា ។ ការបន្តពង្រឹងនូវភាពជាដៃគូជាមួយគ្រប់បណ្ដាភាគីដែលពាក់ព័ន្ធទាំងអស់ និងដោយទូលំទូលាយ កាន់តែមានសារៈសំខាន់ខ្លាំងឡើង នៅពេលដែលបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍ នាពេលបច្ចុប្បន្នរឹតតែមានលក្ខណៈស្មុគស្មាញ និង ពហុទិដ្ឋភាព ។ រាជរដ្ឋាភិបាលកម្ពុជាសូមផ្ដល់នូវការធានាម្ដងហើយម្ដងទៀតចំពោះការប្រើប្រាស់ធនធានសហប្រតិបត្តិការដែលផ្ដល់ដោយដៃគូអភិវឌ្ឍន៍ ឱ្យបានប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និង គណនេយ្យភាព ។ ខ្ញុំរំពឹងយ៉ាងមុតមាំថា យើងនឹងបន្តកិច្ចសហការ និង សហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគ្នាតទៅទៀត ដោយឈរលើស្មារតីនៃភាពជាដៃគូពិតប្រាកដ និង ស្មោះត្រង់ និងដោយគោរពនូវ ***«ភាពជាម្ចាស់»*** របស់កម្ពុជា ។

**40.** ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះសមានចិត្តល្អប្រសើរដែលដៃគូអភិវឌ្ឍន៍ទាំងអស់មានសម្រាប់កម្ពុជា ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** គឺជាអ្នកដឹកនាំប្រកបដោយបទពិសោធន៍ និង ពោរពេញដោយសមត្ថភាព នឹងនៅតំណាងឱ្យរាជរដ្ឋាភិបាល រួមជាមួយនឹងបណ្ឌិត **អ៊ូន ព័ន្ធមុនីរ័ត្ន** ក្នុងឋានៈជាប្រធានបម្រុង សម្រាប់ដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ៣ នេះ ។ សហការីរបស់ខ្ញុំនឹងនៅជាមួយអស់លោកអ្នក ហើយធ្វើការចែករម្លែកជាមួយអស់លោកអ្នកទាំងអស់គ្នា នូវរាល់កម្មវិធី និង ព័ត៌មានលម្អិតទាំងឡាយដែលពាក់ព័ន្ធនឹងទិដ្ឋភាពនានាស្តីពីស្ថានភាព និង សេចក្តីត្រូវការរបស់យើង ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

**41.** ខ្ញុំសូមជូនពរដល់អស់លោកអ្នកទាំងអស់គ្នា សូមប្រកបដោយសុខភាពល្អ និង ជ័យជំនះក្នុងគ្រប់ភារកិច្ច និង សូមជូនពរឱ្យ **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ៣** ប្រព្រឹត្តិទៅបានប្រកបដោយជោគ-ជ័យដ៏ត្រចះត្រចង់ ។

***សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ !***